ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ២៣៧៥ ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨  ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញ អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញ អនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា
- បានឃើញ អនុក្រឹត្យលេខ ២៧០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៧ នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរចាំបាច់នៃការងារ។

## សម្រេច

**ប្រការ ១.–**

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធី និងលក្ខណ្ឌនៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សំដៅធានាដល់ការអនុវត្តន៍កាតព្វកិច្ច សិទ្ធិ និងផលប្រយោជន៍នានារបស់ប្រជាពលរដ្ឋ តាមច្បាប់កំណត់ ។

**ប្រការ ២.–**

ក្រសួងមហាផ្ទៃ ប្រគល់សមត្ថកិច្ច ជូនអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដឹកនាំ ជំរុញ ណែនាំ និងសម្របសម្រួលការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ។

អភិបាលរាជធានី ខេត្តមានភារកិច្ចទទួលខុសត្រូវដឹកនាំចាត់តាំងអនុវត្តការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងជាអ្នកចុះហត្ថលេខាលើបញ្ជីរាយនាមប្រជាពលរដ្ឋដែលបានបំពេញបែបបទសុំផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលប្រជាពលរដ្ឋបានបំពេញបែបបទសុំធ្វើ រហូតដល់ថ្ងៃទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

**ប្រការ ៣.–**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុពី១៥ឆ្នាំឡើង ត្រូវទៅធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅស្ថានីយ៍អចិន្ត្រៃយ៍ នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ឬនៅតាមស្ថានីយ៍ចល័ត នៃឃុំ សង្កាត់ របស់ខ្លួន តាមការជូនដំណឹងរបស់អាជ្ញាធរមានសមត្ថកិច្ច។

ប្រជាពលរដ្ឋ ដែលស្នើសុំផ្តល់អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរត្រូវ ៖

- បង្ហាញមុខដោយផ្ទាល់ជាមួយក្រុមមន្ត្រីនគរបាលជំនាញ និងត្រូវភ្ជាប់មកជាមួយនូវ៖
    - សំបុត្រកំណើតបញ្ជាក់សញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូចាស់ (ចំពោះអ្នកដែលស្នើសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា)ឬ
    - ព្រះរាជក្រឹត្យស្តីពីការផ្តល់សញ្ជាតិខ្មែរ ឬ
    - សាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាជននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ឬ
    - ឯកសារ ឬភស្តុតាងជាផ្លូវការដែលបញ្ជាក់ថា សាមីជនកើតមកពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ និង
    - សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ។
- បំពេញសលាកប័ត្រសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដោយសរសេរឲ្យបានត្រឹមត្រូវច្បាស់លាស់ដូចឯកសារសំអាងដែលបានភ្ជាប់មកជាមួយ

- ផ្តិតខ្មៅដៃ ថតរូប ចុះហត្ថលេខា
- បង់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ តាមការកំណត់ នៃប្រកាសអន្តរក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទទួលយកបង្កាន់ដៃបង់ប្រាក់ សម្រាប់បង្ហាញអាជ្ញាធរមានសមត្ថកិច្ច នៅពេលទទួលយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

មិនត្រូវបានអនុញ្ញាតផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំពោះជនទាំងឡាយណាដែល ៖

- កំពុងបំពេញជាបព្វជិតក្នុងព្រះពុទ្ធសាសនា
- កំពុងអនុវត្តទោសតាមសាលក្រម ឬសាលដីការបស់តុលាការ
- វិកលចរិក
- កំពុងឋិតក្នុងមណ្ឌលអប់រំកែប្រែ
- មានឯកសារផ្លូវការពុំទាន់គ្រប់គ្រាន់ថាខ្លួនមានសញ្ជាតិខ្មែរ ។

**ប្រការ ៤.-**

ការធ្វើសម្រង់បញ្ជីឈ្មោះប្រជាពលរដ្ឋដែលត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ៖

- ប្រធានភូមិ មន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាល ស្មៀនឃុំ សង្កាត់ សហការធ្វើសម្រង់បញ្ជីឈ្មោះប្រជាពលរដ្ឋដែលមានអាយុពី១៥ឆ្នាំឡើង ដោយពិនិត្យផ្ទៀងផ្ទាត់តាមសំបុត្រកំណើត សៀវភៅស្នាក់នៅ "ក២" ឬសៀវភៅគ្រួសារ "ក៤" ឬឯកសារភស្តុតាងបញ្ជាក់សញ្ជាតិខ្មែរផ្សេងទៀតដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ
- នាយប៉ុស្តិ៍នគរបាលរដ្ឋបាល មេឃុំ ចៅសង្កាត់ អធិការនគរបាលក្រុង ស្រុក ខណ្ឌ និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យ និងចុះហត្ថលេខាទទួលខុសត្រូវ លើសម្រង់បញ្ជីឈ្មោះប្រជាពលរដ្ឋដែលត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

**ប្រការ ៥.-**

ការបំពេញបែបបទប្រមូល និងបញ្ជូនទិន្នន័យ សម្រាប់ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ៖

- អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌត្រូវ៖
  - ចាត់មន្ត្រីនគរបាលជំនាញបំពេញបែបបទប្រមូលទិន្នន័យនៅតាមស្ថានីយ៍អចិន្ត្រៃយ៍នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ឬស្ថានីយ៍ចល័តនៅតាមឃុំ សង្កាត់
  - បញ្ជូនទិន្នន័យទៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដើម្បីធ្វើបញ្ជីរាយនាមប្រជាពលរដ្ឋដែលបានបំពេញបែបបទសុំផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររួចហើយ សុំការពិនិត្យសម្រេចពីអភិបាលរាជធានី ខេត្ត

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវបញ្ជូនបញ្ជីរាយនាមប្រជាពលរដ្ឋ ដែលបានពិនិត្យសម្រេចរួចដោយអភិបាលរាជធានី ខេត្ត និងទិន្នន័យទៅមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរបស់ក្រសួងមហាផ្ទៃ សម្រាប់ធ្វើការបោះពុម្ពអត្តសញ្ញាណប័ណ្ណ

- ក្នុងករណីចាំបាច់ តាមសំណើរបស់ក្រសួង ស្ថាប័ននានា អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អាចចាត់មន្ត្រីនគរបាលជំនាញ៖
  - បំពេញបែបបទប្រមូលទិន្នន័យសម្រាប់ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូន មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ កម្មករនិយោជិត ដែលប្រមូលផ្តុំនៅទីកន្លែងបំពេញការងារ
  - ធ្វើបញ្ជីឈ្មោះមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ កម្មករនិយោជិត ដែលបានបំពេញបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររួចហើយ ដើម្បីសុំការពិនិត្យសម្រេចពីអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
  - ធ្វើការបោះពុម្ពអត្តសញ្ញាណប័ណ្ណ និងប្រគល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលបោះពុម្ពរួចជូនទៅសាមុីក្រសួង ស្ថាប័នដែលស្នើសុំដោយមានកំណត់ហេតុប្រគល់ទទួលត្រឹមត្រូវច្បាស់លាស់
  - បញ្ជូនសំណុំឯកសារនិងទិន្នន័យ ដែលបានផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររួច ទៅស្នង-ការដ្ឋាននគរបាលរាជធានី ខេត្ត ដែលជាទីលំនៅអចិន្ត្រៃយ៍របស់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ កម្មករនិយោជិត ដើម្បីបានជ្រាប និងបន្តការគ្រប់គ្រង។

**ប្រការ ៦ .-**

ប្រជាពលរដ្ឋពេលទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មាន នៅលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួន ដូចជា ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ ទីកន្លែងកំណើត អាសយដ្ឋាន ឬព័ត៌មានផ្សេងៗទៀត។

ក្នុងករណីពិនិត្យឃើញថា មានព័ត៌មានខុសពីព័ត៌មាននៅក្នុងឯកសារឬភស្តុតាងផ្លូវការនានាដែលសាមីខ្លួនបានផ្តល់ជូនអាជ្ញាធរមានសមត្ថកិច្ច នៅពេលបំពេញបែបបទស្នើសុំធ្វើអត្តសញ្ញាណប័ណ្ណ សាមីខ្លួនត្រូវតវ៉ាទៅនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ឬអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌនៃលំនៅដ្ឋានរបស់ខ្លួន ដោយភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណដែលមានព័ត៌មានខុស និងឯកសារភស្តុតាងផ្លូវការនានា ដែលផ្តល់ជូនអាជ្ញាធរមានសមត្ថកិច្ច នៅពេលបំពេញបែបបទស្នើសុំធ្វើអត្តសញ្ញាណប័ណ្ណ។

បន្ទាប់ពីទទួលការតវ៉ាពីប្រជាពលរដ្ឋ៖

- នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ឬអធិការ នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារដែលពាក់ព័ន្ធនានា រួចរៀបចំបញ្ជូនសំណើសុំកែតម្រូវ ដោយភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណដែលខុស និងឯកសារដែលពាក់ព័ន្ធទៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវពិនិត្យផ្ទៀងផ្ទាត់និងរៀបចំសំណុំឯកសារបញ្ជូនទៅអភិបាលរាជធានី ខេត្ត ស្នើសុំការពិនិត្យសម្រេច រួចបញ្ជូនទៅអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ពិនិត្យសម្រេចកែតម្រូវទិន្នន័យ និងបោះពុម្ពអត្តសញ្ញាណប័ណ្ណថ្មី។

ការកែតម្រូវព័ត៌មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលបានទទួលការតវ៉ាសុំកែតម្រូវរបស់ប្រជាពលរដ្ឋនៅអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ រហូតដល់ថ្ងៃប្រគល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលបានកែតម្រូវរួចជូនប្រជាពលរដ្ឋ។

**ប្រការ ៧ .-**

ប្រជាពលរដ្ឋដែលទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ រួចហើយ ត្រូវថែរក្សាឲ្យបានល្អ បង្ការការបាត់ ឬខូចដើម្បីទុកប្រើប្រាស់ជាប្រយោជន៍ផ្សេងៗតាមការកំណត់នៃច្បាប់។

**ប្រការ ៨ .-**

ត្រូវបានដកហូតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាបណ្តោះអាសន្ន និងឬជាស្ថាពរក្នុងករណី៖

- ជនដែលមានសាលក្រម ឬសាលដីការបស់តុលាការបង្គាប់ឲ្យដកហូត
- ជនគ្មានសញ្ជាតិខ្មែរ តែមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

**ប្រការ ៩ .-**

ក្នុងករណីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបានបាត់ សាមីខ្លួន ត្រូវប្តឹងដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលនៅឃុំ សង្កាត់ដែលកើតឡើងការបាត់ មិនលើស២៤ម៉ោងបន្ទាប់ពីដឹងថាបាត់។ ប្រសិនបើការបាត់កើតឡើងក្រៅឃុំ សង្កាត់របស់ខ្លួន សាមីខ្លួន ត្រូវជូនដំណឹងដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលនៅឃុំ សង្កាត់ ដែលខ្លួនកំពុងរស់នៅមិនលើស ៤៨ម៉ោងបន្ទាប់ពីវិលត្រឡប់ដល់លំនៅដ្ឋានវិញ។

ករណីដែលសមត្ថកិច្ចពិនិត្យឃើញថា ជននោះពិតជាបាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រាកដមែន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ"ទុតិយតា" និងត្រូវបានផ្តល់ជូន ក្នុងរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលបានទទួលបណ្តឹង ឬដំណឹង និងសាមីខ្លួនបានបំពេញសំណុំលិខិតគ្រប់គ្រាន់។

ក្នុងករណីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបានខូច ឬអស់សុពលភាព សាមីខ្លួនត្រូវទៅបំពេញបែបបទស្នើសុំផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ "ទុតិយតា" នៅស្ថានីយ៍អចិន្ត្រៃយ៍ នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ឬនៅតាមស្ថានីយ៍ចល័តនៃឃុំ សង្កាត់ របស់ខ្លួនរស់នៅដោយភ្ជាប់មកជាមួយសន្លឹកអត្តសញ្ញាណប័ណ្ណដែលខូច ឬ អស់សុពលភាព។

**ប្រការ ១០ .-**

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានសុពលភាព ១០ឆ្នាំ ។ មុនពេលអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អស់សុពលភាពរយៈពេល ៩០ថ្ងៃ សាមីខ្លួនត្រូវសុំធ្វើសាជាថ្មីឡើងវិញ "ទុតិយតា" ។ នីតិវិធីនៃការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា ត្រូវបំពេញសំណុំលិខិតដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ។

**ប្រការ ១១ .–**

ត្រូវទទួលទណ្ឌកម្មរដ្ឋបាលឬ/និង ទទួលទោសតាមច្បាប់ជាធរមានចំពោះជនណាដែលៈ

- រាយការណ៍ចុះឈ្មោះផ្តល់ព័ត៌មានខុសពីការពិតក្នុងសំណុំបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- គ្មានសញ្ជាតិខ្មែរ ប៉ុន្តែកាន់កាប់ ឬប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ក្លែង កោស លុប ឲ្យអ្នកដទៃខ្ចី ឬសរសេរត្រួតក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- មានចេតនាជួយសម្រួលសំណុំបែបបទ ឬ សម្រេចផ្តល់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឲ្យជនដែលគ្មានសញ្ជាតិខ្មែរ ។

**ប្រការ ១២ .–**

ប្រកាសលេខ៦៨៨ ប្រក. ចុះថ្ងៃទី ០៦ខែមីនា ឆ្នាំ២០១២ ស្តីពីនីតិវិធី លក្ខខណ្ឌនៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងបទប្បញ្ញត្តិណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១៣ .–**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងមហាផ្ទៃ អភិបាលរាជធានី ខេត្ត ប្រធានអង្គភាពពាក់ព័ន្ធនានា និងស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ